**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ១០៥ សរណន

CAMBODIA
Kingdom of Wonder
feel the warmth

ថ្ងៃ អង្គារ ១០រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០២២

# សារាចរណែនាំ

## ស្ដីពី

## ការលើកលែង "កាតព្វកិច្ចពាក់ម៉ាស់" នៅតាមទីតាំងអាជីវកម្មសេវាកម្មទេសចរណ៍

អនុវត្តតាមសារសម្លេងពិសេសរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ក្រសួងទេសចរណ៍ សូមជម្រាបជូន ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ស្ថាប័នពាក់ព័ន្ធ និងប្រតិបត្តិករទេសចរណ៍ទាំងអស់ ជ្រាបថា៖

១)- រាជរដ្ឋាភិបាលបានសម្រេចលើកលែង "**កាតព្វកិច្ចពាក់ម៉ាស់**" នៅទូទាំងប្រទេស ចំពោះទីកន្លែងសាធារណៈ និងទីកន្លែងចំហរនានា ក្រៅអំពីកន្លែងបិទជិត។ ដូចនេះ នៅគ្រប់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ អាចជ្រើសរើសដោយខ្លួនឯងពីការបន្តពាក់ម៉ាស់ ឬមិនពាក់ម៉ាស់ នៅក្នុងបរិវេណទីកន្លែងសាធារណៈ និងទីកន្លែងចំហរនានា។ ឧទាហរណ៍៖ នៅតាមរមណីយដ្ឋានធម្មជាតិនានាដែលមិនកកកុញ ឬនៅក្នុងបរិវេណខាងក្រៅនៃមូលដ្ឋានអាជីវកម្មទេសចរណ៍ (សណ្ឋាគារ ភោជនីយដ្ឋាន។ល។) ដែលមានខ្យល់ចេញ-ចូល និងមិនកកកុញជាដើម

២)- ដោយឡែកនៅក្នុងបរិវេណកន្លែងបិទជិត ដូចជា៖ បន្ទប់ប្រជុំបិទជិតមានម៉ាស៊ីនត្រជាក់ បន្ទប់ខារ៉ាអូខេ ក្លឹបកម្សាន្ត បន្ទប់ម៉ាស្សា និងទីកន្លែងផ្ដល់សេវាកម្មទេសចរណ៍ផ្សេងទៀតដែលស្ថិតក្នុងទម្រង់ជាបន្ទប់បិទជិតត្រូវបន្តអនុវត្ត "**កាតព្វកិច្ចពាក់ម៉ាស់**"

៣)- រាជរដ្ឋាភិបាលនៅតែបន្តលើកទឹកចិត្តដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ទាំងអស់នៅតែបន្តពាក់ម៉ាស់ នៅកន្លែងដែលមានមនុស្សកកកុញ ប្រមូលផ្ដុំ និងនៅទីកន្លែងដែលមានករណីសង្ស័យជំងឺកូវីដ-១៩

៤)- មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវបន្តអនុវត្ត **វិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្ដង់ដារអប្បបរមា** (SOP) ដោយសម្រួល និងលើកលែងការអនុវត្តចំពោះរាល់ចំណុចពាក់ព័ន្ធនឹង "**កាតព្វកិច្ចពាក់ម៉ាស់**" (ទាំងចំពោះភ្ញៀវ ទាំងចំពោះបុគ្គលិក និងសាធារណជនទូទៅ) ស្របតាមស្មារតីដូចមានបញ្ជាក់ ក្នុងចំណុចទី១ ទី២ និងទី៣ ខាងលើ។

៥)- មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវបន្តអនុវត្តតាមគោលការណ៍ណែនាំផ្សេងទៀតដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍ និងក្រសួងសុខាភិបាល ដើម្បីបន្តចូលរួមក្នុងយុទ្ធនាការប្រឆាំងនឹងជំងឺកូវីដ-១៩។

ទទួលបានសារាចរណែនាំនេះ សូម ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ស្ថាប័នពាក់ព័ន្ធ និងប្រតិបត្តិករទេសចរណ៍ទាំងអស់ អនុវត្តខ្លឹមសារខាងលើនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្ដេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
- គ្រប់សមាគមឧស្សាហកម្មទេសចរណ៍
- ឯកសារ កាលប្បវត្តិ